**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ២៥០/០០៧/២០១៤

ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤

**សេចក្តីសម្រេច**

លេខ : ១៥០/០០៤/២០១៤ កបធ.ច

ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញលិខិតលេខ ៣៣២ រ.ស ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ របស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្នើសុំក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពលើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលលិខិតខាងលើនេះនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ វេលាម៉ោង ១០ និង ២០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**

**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

- យល់ឃើញថា រដ្ឋសភាបានអនុវត្តត្រឹមត្រូវតាមបទប្បញ្ញត្តិនៃមាត្រា ៨២ ថ្មី វាក្យខ័ណ្ឌទី៣ មាត្រា ៩៤ នៃរដ្ឋធម្មនុញ្ញ និងប្រការ ៨២ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា ក្នុងការពិនិត្យនិងអនុម័តសេចក្តីស្នើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- យល់ឃើញថា សំណើរបស់សម្តេចអគ្គមហាពញាចក្រី **ហេង សំរិន** ប្រធានរដ្ឋសភា ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និងមាត្រា ១៦ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ។ ដូច្នេះ ក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើសុំពិនិត្យធម្មនុញ្ញ-ភាពលើវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានេះមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងនិងការអនុម័តវិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា ខ្លឹមសារនៃប្រការ ៦ ថ្មី (ពីរ) នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រ-កម្ពុជា ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញទេ។

## សម្រេច

**មាត្រា ១.** វិសោធនកម្មប្រការ ៦ ថ្មី នៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ។

**មាត្រា ២.** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤ ក្នុងកិច្ចប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល